# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
### <u>កិច្ចព្រមព្រៀង</u>

ស្តីពីការព្យួរកិច្ចសន្យាការងាររវាង **តំណាងកម្មករនិយោជិត និងរោងចក្រ ផេកជឺ អ៊ិនធើណេសិនណល(ខាមបូឌា)** កាលពីថ្ងៃទី២០ ខែ មិថុនា ឆ្នាំ ២០២១ វេលាម៉ោង៨ និង ០០ នាទី មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារក្នុង រោងចក្រ ផេកជឺ អ៊ិនធើណេសិនណល(ខាមបូឌា) ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ ភូមិ ព្ញធឿង ឃុំ រាម ស្រុក ព្រៃនប់ ខេត្ត ព្រះសីហនុ។

<u>សមាសភាពដែលចូលរួមក្នុងអង្គប្រជុំមាន ៖</u>

| | | |
|---|---|---|
| **ក. ភាគីនិយោជក(តំណាងអោយក្រុមហ៊ុន)៖** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
| ឈ្មោះ អ៊ឹង ម៉េងទីវ | អនុ. ប្រធានគ្រប់គ្រងផ្នែកធនធានមនុស្ស | ០១០៣០០០៣៧ |
| **ខ. ភាគីកម្មករនិយោជិត(តំណាងអោយកម្មករ)** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
| ឈ្មោះរ៉េម សាលេស | ប្រតិភូបុគ្គលិក | ០៨៦៦៩៦០០៨ |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងារ សមស្របតាមសេចក្តីណែនាំលេខៈ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់ភាគីទាំងសងខាងបានឯកភាពយល់ព្រមបន្តព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតទាំងអស់ចំនួន៥៨ នាក់ (ស្រី៤៣នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ចំនួន ៥៨នាក់ (ស្រី៤៣នាក់) ក្នុងរយៈ១៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០២១ដល់ថ្ងៃទី១០ ខែ កក្កដា ឆ្នាំ ២០២១ ដោយទទួលបានប្រាក់ ឧបត្ថមពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ ដុល្លាអាមេរិចក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ ដោយឡែក សម្រាប់ រោងចក្រ ផេកជឺ អ៊ិនធើណេសិនណល(ខាមបូឌា) ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថមបន្ថែមដល់ បុគ្គលិកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារខាងរោងចក្រ ទទួលរងផលប៉ះពាល់ខ្លាំងពីជម្ងឺ Covid-19 និងបានបាត់បង់ប្រាក់ចំណូល។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង៩ និង ៣០ នាទី នាថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០២១ ដោយមានចុះហត្ថលេខាព្រមព្រៀងពីតំណាងទាំងពីរ ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីទាំងសងខាងដោយបានចុះហត្ថលេខាដូចខាងក្រោម៖

| | |
|---|---|
| **ភាគីតំណាងឲ្យនិយោជក** | **ភាគីតំណាងឲ្យកម្មករនិយោជិត** |
| ហត្ថលេខា/ស្នាមមេដៃ | ហត្ថលេខា/ស្នាមមេដៃ |
| PACGEAR INTERNATIONAL (CAMBODIA) Co., Ltd. KINGDOM OF CAMBODIA | |